**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...៨៤...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរំលាយក្រុមហ៊ុនជលផលជាសហគ្រាសសាធារណៈ និងក្រុមប្រឹក្សាភិបាល

## រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០០៣ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអភិវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និងក្រុមហ៊ុនជលផល

-តាមសំណើរបស់គណៈកម្មាធិការជាតិអភិវិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និង ក្រុមហ៊ុនជលផល

## សម្រេច

**មាត្រា ១.-**

រំលាយក្រុមហ៊ុនជលផលជាសហគ្រាសសាធារណៈ ដែលបង្កើតឡើងដោយអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៧ តទៅ។

**មាត្រា ២.-**

រំសាយក្រុមប្រឹក្សាភិបាល មន្ត្រីត្រួតពិនិត្យរដ្ឋ និង ប្រធានអគ្គនាយកក្រុមហ៊ុនជលផល ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៧ តទៅ។

**មាត្រា ៣.-**

ផ្ទេរលោក **ខួ ប៊ុនថា** ប្រធានអគ្គនាយកក្រុមហ៊ុនជលផល ចូលមកបំរើការងារក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទវិញ ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៧ តទៅ។

**មាត្រា ៤.-**

រាល់បំណុលភ្នំរើទាំងអស់ដែលអតិថិជនជំពាក់ក្រុមហ៊ុនជលផល ចំនួន ១២.៦១៦ (ដប់ពីរពាន់ប្រាំមួយរយដប់ប្រាំមួយ) ដុល្លារអាមេរិក និង ៧.៥០០.០០០(ប្រាំពីរលានប្រាំរយពាន់)រៀល ត្រូវផ្ទេរមករដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ទទួលបន្ទុកដោះស្រាយបន្ត ។

**មាត្រា ៥.-**

ប្រាក់កក់របស់ក្រុមហ៊ុនជលផលសំរាប់ការតបណ្តាញអគ្គីសនី ចំនួន ៤.៧២៥.០០០ (បួនលានប្រាំពីររយម្ភៃប្រាំពាន់)រៀល ត្រូវផ្ទេរមករដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ទទួលបន្ទុកបន្ត ។

**មាត្រា ៦.-**

ក្រុមហ៊ុនជលផល ត្រូវប្រគល់ត្រាក្រុមហ៊ុន និង ឯកសារពាក់ព័ន្ធទាំងឡាយ រួមទាំងឯកសារក្នុងកុំព្យូទ័រ មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីរក្សាទុក។

**មាត្រា ៧.-**

ថវិកាដែលនៅសល់ក្នុងគណនីទាំងអស់របស់ក្រុមហ៊ុនជលផលត្រូវបង្វែរចូលថវិការដ្ឋ។

បិទរាល់គណនីធនាគារទាំងអស់របស់ក្រុមហ៊ុនជលផល ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៧ តទៅ។

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៧ តទៅ ។

**មាត្រា ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការជាតិអភិវឌ្ឍន៍... 

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៧

ហ៊ុន សែន

<u>**កន្លែងទទួល**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមានក្នុងមាត្រា ៩
- ឯកសារ-កាលប្បវត្តិ